ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***

ឆ្នាំទី ៤ លេខ ២២ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

មាតិកា

I ទីស្ដីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

១៦.៦.៩៦	អនុក្រឹត្យលេខ ២៤ អនក្រ.បក ស្ដីពីការបែងចែកឥណទានជំពូក ៥០ (ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក)	៩២៣
១២.៦.៩៦	អនុក្រឹត្យលេខ ២៥ អនក្រ.បក ស្ដីពីការដកខ្ទង់ចំណាយឥតគ្រោងទុក	៩២៦
១២.៦.៩៦	អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្ដីពីការបង្កើតស្រុកកំពង់សីលាចំណុះខេត្តកោះកុង	៩២៧
១១.៦.៩៦	អនុក្រឹត្យលេខ ១០៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៩២៨
១១.៦.៩៦	អនុក្រឹត្យលេខ ១០៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៩២៩
១១.៦.៩៦	អនុក្រឹត្យលេខ ១០៧ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៩៣០
១១.៦.៩៦	អនុក្រឹត្យលេខ ១០៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៩៣១
១១.៦.៩៦	អនុក្រឹត្យលេខ ១០៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៩៣២
១១.៦.៩៦	អនុក្រឹត្យលេខ ១១០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៩៣៤

២—សេចក្ដីសម្រេច

១២.៦.៩៦	សេចក្ដីសំរេចលេខ ២០ សសរ ស្ដីពីការផ្ទេរសិទ្ធិ	៩៣៥
១៣.៦.៩៦	សេចក្ដីសំរេចលេខ ២១ សសរ ស្ដីពីការបង្កើតប្រធានគណៈកម្មការរៀបចំបុណ្យជាតិ	៩៣៦

II ការងារបណ្ដាក្រសួង

១—ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

១១.៦.៩៦	ប្រកាសលេខ ០៨០ សហវ.ប្រក ស្ដីពីការបង្កើតគណៈកម្មការបច្ចេកទេសសម្របសម្រួល និង កែទម្រង់រដ្ឋបាលប្រចាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	៩៣៨
១៣.៦.៩៦	ប្រកាសលេខ ១៧១ សហវ.ប្រក ស្ដីពីការបង្កើតការិយាល័យពត៌មានវិទ្យា	៩៤០
១៣.៦.៩៦	ប្រកាសលេខ ១៧២ ប្រកសហវ.ពជ ស្ដីពីការបង្កើតការិយាល័យវិវាទ	៩៤២
១៤.៦.៩៦	ប្រកាសលេខ ១៧៤ ប្រក.សហវគរ ស្ដីពីការតែងតាំង និង ផ្ទេរភារកិច្ចមន្ត្រីគយ និង រដ្ឋាករ	៩៤៤

២—ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

១០.៦.៩៦	ប្រកាសលេខ ៣៧៤ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន យិងចាងកម្ពុជា កាត់ដេរសំលៀកបំពាក់នាំចេញ (JIN CHAN CAMBODIA CLOTHING Co.LTD)	៩៥៥
១០.៦.៩៦	ប្រកាសលេខ ៣៧៥ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនស្បែកជើងដុងដាកម្ពុជា ខិលធីឌី (DONG DA SHOES CAMBODIA COMPANY LTD ផលិតស្បែកជើងសំរាប់នាំចេញ	៩៥៦
១០.៦.៩៦	ប្រកាសលេខ ៣៧៦ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនភ្នំពេញថ្មីហ្គាមែន (PHNOM PENH THMEY GARMENT LTD) បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់សំរាប់នាំចេញ	៩៥៧

១០.៦.៩៦ ប្រកាសលេខ ៣៧៧ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនម៉ាយធីស្ពិកត្រាណាយធីងហ្វិកថ្វ៉ី SPECTRA KNITTING FACTORY Co.LTD) បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ សំរាប់នាំចេញ ៩៥៨

១០.៦.៩៦ ប្រកាសលេខ ៣៧៨ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ខេមបូឌាស្តូរេជបាតេរី លីមីធិត (CAMBODIA STORAGE BATTERY Co.LTD) បង្កើតរោងផលិតអាគុយសំរាប់នាំចេញ ៩៥៩

៥—ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

១០.៦.៩៦ ប្រកាសលេខ ៤៤៦ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅសំរាប់គ្រូ «វិទ្យាសាស្ត្រអនុវត្តន៍ថ្នាក់ទី ១ » ៩៦០

១០.៦.៩៦ ប្រកាសលេខ ៤៤៧ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅសំរាប់សិស្ស «វិទ្យាសាស្ត្រអនុវត្ត ថ្នាក់ទី ១ » ៩៦១

១១.៦.៩៦ ប្រកាសលេខ ៥៣៨ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបើកសាលាបឋមសិក្សា ចំណេះទូទៅ ឯកជនខ្មែរ–ចិន ៩៦២

I ទីស្តីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ២៤ អនក្រ.បក

ស្តីពីការបែងចែកឥណទាន

ជំពូក ៥០ (ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក)

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ។

– បានឃើញព្រះរាជក្រឹត្យ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។

– បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស.រកម.០១៩៦.១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។

– បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

– បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខនស.រកម.១២៩៥.០៧ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៥ ។

– បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែងឥណទានផ្ទៃក្នុងជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៦ ។

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

សំរេច

មាត្រា ១ : អនុញ្ញាតិអោយបែងចែកឥណទានជំពូក ៥០.០១ (ឥណទានសាងសង់ និង ទព្វសំភារៈ) ចំនួន ៣០.៦១៥ លានរៀល (សាមសិបពាន់ប្រាំមួយរយដប់ប្រាំលាន - រៀល) និង ជំពូក ៥០.០២ (បរិភាគជារូបិយវត្ថុក្នុងស្រុក នៃហិរញ្ញប្បទានផ្ទាល់ពីបរទេស) ចំនួន ១៣.៣៦០ លានរៀល (ដប់បីពាន់បីរយហុកសិបលានរៀល) ជូនទៅបណ្តាក្រសួង ស្ថាប័ននានាដូចខាងក្រោមនេះ ÷

លេខកូដ	ក្រសួង ស្ថាប័ន	ជំពូក ៥០.០១	ជំពូក ៥០.០២	ផ្សេងៗ
០១	ព្រះបរមរាជវាំង	៣.៣៤៩		
០២	រដ្ឋសភា	៣០០		
០៣	គណៈរដ្ឋមន្ត្រី	២.៥៤១	៦០	
០៣.១	ទីស្តីការគណៈរដ្ឋមន្ត្រីផ្ទាល់	២.៥៤១		
០៣.២	អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា		៦០	
០៤	ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	១៣២		
០៦	ក្រសួងមហាផ្ទៃ	៥៥៣	៣.៥០៣	
០៦.១	រដ្ឋបាលទូទៅ	៥៥៣	-	
០៦.៩	ខេត្ត-ក្រុងនានា		៣.៥០៣	សំរាប់រោងករទឹកភ្នំពេញ
០៧	ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	៥.១៧០	២.០០៩	សំរាប់ត្រៀមបែងចែក
០៨	ក្រសួងពត៌មាន	២៥០		
០៩	ក្រសួងសាធារណការ និង ដឹកជញ្ជូន	១០.៦៦០	២.៣២៧	
១០	ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ		៣៦៤	
១១	ក្រសួងយុត្តិធម៌	២៥០		
១៣	ក្រសួងពាណិជ្ជកម្ម	៦០		

១៤	ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល	២១៤	៤.៩៣២	
១៥	ក្រសួងផែនការ	៤០០		
១៧	ក្រសួងទេសចរណ៍	៣០០		
១៨	ក្រសួងធម្មការ និង កិច្ចការសាសនា	៦៦៩		
១៩	ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	២៩៩		
២០	ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ		១៥	
២១	ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន	១.៧៩៨		
២២	ក្រសួងបរិស្ថាន	៣០៥		
២៣	ក្រសួងអភិវឌ្ឍន៍ជនបទ	៣.០១៥	១៥០	
២៤	ក្រសួងកិច្ចការនារី	៣៥០		
	សរុប	៣០.៦១៥	១៣.៣៦០	

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី នៃក្រសួងស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះ ហស្តលេខា និង ចុះហត្ថលេខានេះតទៅ ÷

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ២៥ អនក្រ.បក

ស្តីពីការដកខ្ទង់ចំណាយឥតគ្រោងទុក

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រឹត្យ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស.រកម.១២៩៥.០៧ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៥ ។
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៦ ការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៦ ។
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

សំរេច

មាត្រា ១ : អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដកថវិកាជារូបិយប័ណ្ណក្នុងខ្ទង់ចំណាយឥតគ្រោង ទុកចំនួន១.៤០២.៩២៨,០០$US (មួយលានបួនរយពីរពាន់ប្រាំបួនរយម្ភៃប្រាំបីដុល្លារអាមេរិកគត់) សំរាប់ដោះស្រាយ ។

- បន្ថែមចំណាយសាងសង់បន្ទាយសុវត្ថិភាពសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ ចំនួន ៦៨៣.០៩៨ $ ។

- បន្ថែមចំណាយសាងសង់បន្ទាយសុវត្ថិភាពសម្តេចនាយករដ្ឋមន្ត្រីទី២ចំនួន ៧១៩.៨៣០ រៀល ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ២៦ អនក្រ.បក

ស្តីពីការបង្កើត ស្រុក កំពង់សីលា

ចំណុះខេត្តកោះកុង

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២នៃរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

សំរេច

មាត្រា ១ : ត្រូវបានបង្កើតស្រុកកំពង់សីលា ដោយកាត់យកភូមិសាស្ត្រស្រុកស្រែអំបិល នៃខេត្តកោះកុងទៅតាមផែនទីរដ្ឋបាលភ្ជាប់ជាមួយអនុក្រឹត្យ ។

មាត្រា ២ :ស្រុកកំពង់សីលាត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តកោះកុង ។

មាត្រា ៣ :ស្រុកកំពង់សីលារួមមានឃុំចំនួន ០៤ គឺឃុំស្ទឹងឆាយ ឃុំចំការហ្លួង ឃុំកំពង់សីលា និង ឃុំអូរបាក់រនេះ ។

មាត្រា ៤ :ស្រុកកំពង់សីលា មានព្រំប្រទល់រដ្ឋបាល

-ខាងជើងជាប់នឹងស្រុកស្រែអំបិល ខេត្តកោះកុង

-ខាងត្បូងជាប់នឹងខេត្តកំពត និង ក្រុងព្រះសីហនុ

-ខាងលិចជាប់នឹងស្រុកស្រែអំបិល ខេត្តកោះកុង

-ខាងកើតទល់នឹងខេត្តកំពង់ស្ពឺ និង ខេត្តកំពត

មាត្រា ៥ :ទីតាំងសាលាស្រុកកំពង់សីលា ស្ថិតនៅឃុំកំពង់សីលា ។

មាត្រា ៦ :បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១០៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រឹត្យ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

សំរេច

មាត្រា ១ :ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិជូនលោក **គង់ ឫទ្ធិជាញ** នាយកក្លិបយុវជនអន្តរជាតិដែលបានជួយកសាងអាគារសិក្សា ០១ ខ្នងមាន ០៥ បន្ទប់ជូនប្រជាជននៅក្នុងឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល អស់ទឹកប្រាក់ ២២.០០០$ ។

មាត្រា ២ :សហរដ្ឋមន្ត្រីទទួលបន្ទុកទិស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្ត កណ្តាលត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១០៦ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ។

– បានឃើញព្រះរាជក្រឹត្យ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។

– តាមសំណើរបស់អភិបាលខេត្ត សៀមរាប ។

សំរេច

មាត្រា ១ :ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិជូនលោក THOMAS BOVET សញ្ជាតិអាល្លឺម៉ង់ ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនចំនួន ៣៥.៥០០ $ សំរាប់សាងសង់អាគារសិក្សាថ្មី ០១ ខ្នង និង ជួសជុលអាគារសិក្សាចាស់ ០២ ខ្នង ស្ថិតនៅក្នុងឃុំល្វេស ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។

មាត្រា ២ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល ខេត្តសៀមរាបត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១០៧ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រីដែលៈ ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រឹត្យ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ។

សំរេច

មាត្រា ១ :ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិជូនចំពោះលោក **ឡើ ហេង** តំណាងក្រុមហ៊ុនសាំងឡេងអន្តរជាតិដែលបានជួយកសាងផ្លូវថ្មីមួយខ្សែមានប្រវែង៣៤៩០ ម៉ែត្រ ដោយ ក្រាលក្រួសក្រហម និង ដាក់លូស្របតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវ ស្ថិតក្នុងសង្កាត់ ភ្នំពេញថ្មី ខ័ណ្ឌឬស្សីកែវ ចំណាយអស់ទឹកប្រាក់សរុប ២៦.៦០០$ ។

មាត្រា ២ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១០៤ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ។

-បានឃើញព្រះរាជក្រឹត្យ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។

-តាមសំណើរបស់អភិបាលខេត្តស្វាយរៀង ។

សំរេច

មាត្រា ១ :ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិជូនចំពោះសប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ចូលរួមចំណែកកសាងប្រទេស ដូចមានរាយនាមខាងក្រោម ÷

១-អង្គការព្រះសង្ឃពុទ្ធសាសនាជប៉ុន «ASIRA» បរិច្ចាគប្រាក់ចំនួន ៣០.១៣០៛ សំរាប់ជីកស្រះទឹក ០៥ កន្លែង ក្នុងស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

២-លោក **សៅ សិរីមុនី ហៅ យ៉ាត់** បរិច្ចាគប្រាក់ ១៥.០០០៛ សំរាប់ធ្វើរបងអនុវិទ្យាល័យមិត្តភាព **ហ៊ុន សែន អ៊ុំខ ផន** ។

មាត្រា ២ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល ខេត្ត ស្វាយរៀងត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១០៩ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ**

ទស្សន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ។

– បានឃើញព្រះរាជក្រឹត្យ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។

– តាមសំណើរបស់អភិបាលកំពង់ចាម ។

សំរេច

មាត្រា ១ :ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិជូនចំពោះសប្បុរសជន ០៣ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនសំរាប់ចូលរួមកសាងជាតិដូចមាននាមខាងក្រោម ÷

១–លោក **ង៉ោ ឡើ** និង ភរិយា បរិច្ចាគប្រាក់២៦.០០០ $ សំរាប់ជួសជុលផ្លូវលំប្រវែង ១៣ គ.ម ក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

២–លោក **ពៅ សេងហាក់** រស់នៅសហរដ្ឋអាមេរិក បរិច្ចាគប្រាក់ ២២.០០០ $ កសាងអាគារ សិក្សា ០១ ខ្នង ក្នុងអនុវិទ្យាល័យចុងជាច ស្រុកតំបែរ ខេត្តកំពង់ចាម ។

៣–លោកយាយ **ផាងម៉ុនហឿង** រស់នៅសហរដ្ឋអាមេរិក បរិច្ចាគប្រាក់ ១០.០០០ $ សំរាប់ជីកស្រះមួយ និង កសាងសាលាឆទានមួយក្នុងស្រុកបាធាយ ខេត្តកំពង់ចាម ។

មាត្រា ២ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល ខេត្តកំពង់ចាមត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឬទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១១០ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រឹត្យ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។
- តាមសំណើរបស់អភិបាលកំពង់ចាម ។

សំរេច

មាត្រា ១ :ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិតាមលំដាប់ថ្នាក់ជូនចំពោះសប្បុរសជន និង ក្រុមហ៊ុនដែលបានបរិច្ចាគ ថវិកាផ្ទាល់សំរាប់ចូលរួមកសាងជាតិ និង ទ្រទ្រង់សមរភូមិមុខ ដូចមាននាមខាងក្រោម ÷

ក–មេដាយមាស :

១–លោក **ចៅ ឡូ** និង ភរិយា បរិច្ចាគប្រាក់ ១៣.០០០ $ កសាងរបងអនុវិទ្យាល័យ សម្តេច **ហ៊ុន សែន** ស្រុកបាធាយ ។

ខ–មេដាយប្រាក់ :

១–ក្រុមហ៊ុនចំការកៅស៊ូ ចំការអណ្តូងបរិច្ចាគប្រាក់ ៥.០០០ $ សំរាប់ទ្រទ្រង់ សមរភូមិមុខ ។

គ–មេដាយសំរិទ្ធ :

១–ក្រុមហ៊ុនចំការកៅស៊ូ បឹងកេត បរិច្ចាគប្រាក់ ៣.៥០០ $ សំរាប់ទ្រទ្រង់ សមរភូមិមុខ ។

២–ក្រុមហ៊ុនចំការកៅស៊ូមេមត់បរិច្ចាគប្រាក់ ៣.០០០ $ សំរាប់ទ្រទ្រង់សមរភូមិមុខ ។

៣–ក្រុមហ៊ុនចំការកៅស៊ូ ជប់ បរិច្ចាគ ២.០០០ $ សំរាប់ទ្រទ្រង់សមរភូមិមុខ ។

៤–ក្រុមហ៊ុនចំការកៅស៊ូ ក្រែក បរិច្ចាគប្រាក់ ២.០០០ $ សំរាប់ទ្រទ្រង់សមរភូមិមុខ ។

៥–ក្រុមហ៊ុនភាពីម៉ិច បរិច្ចាគប្រាក់ ១.២០០ $ សំរាប់ទ្រទ្រង់សមរភូមិមុខ ។

ប្រការ ២ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល ខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

២–សេចក្ដីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៦

សេចក្ដីសំរេចលេខ ២០ សសរ

ស្ដីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

–បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។

–បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ។

–តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ។

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ម៉ុក ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិស្ថាន ជារដ្ឋលេខាធិការ ស្ដីទី នៃក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនជំនួសឯកឧត្តម **ស៊ុយ សែម** ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៨៦ រហូតដល់ ឯកឧត្តមបញ្ចប់បេសកកម្ម ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម **ម៉ុក ម៉ារ៉េត** ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៦

សេចក្ដីសំរេចលេខ ២១ សសរ

ស្ដីពីការបង្កើតប្រធានគណៈកម្មការរៀបចំបុណ្យសព

មាត្រា ១ : ត្រូវបានបង្កើតប្រធានគណៈកម្មការបុណ្យសពសម្ដេចចក្រី **ញឹក ជូឡុង** ឧត្តមទីប្រឹក្សា ព្រះមហាក្សត្រដូចមានរាយនាមខាងក្រោម ÷

១–ឯកឧត្តម **គាត់ ឈំហុល** ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីបរមរាជវាំង ជាប្រធាន

២–ឯកឧត្តម ឧត្តមសេនិយឯក **ទៀ បាញ់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអនុប្រធាន

៣–ឯកឧត្តម ឧត្តមសេនិយឯក **ឌា ចាន់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអនុប្រធាន

៤–ឯកឧត្តម ឧត្តមសេនិយឯក **ខេត បែន** ឧត្តមទីប្រឹក្សាព្រះមហាក្សត្រ ជាសមាជិក

៥–ឯកឧត្តម ឧត្តមសេនិយឯក **កែ គឹមយ៉ាន** នាយអគ្គសេនាធិការ ជាសមាជិក

៦–ឯកឧត្តម ឧត្តមសេនីយឯក **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ ជាសមាជិក

៧–ឯកឧត្តម **ឯក សេរីវឌ្ឍ** រដ្ឋលេខាធិការក្រសួងការពារជាតិ ជាសមាជិក

៨–ឯកឧត្តម ឧត្តមសេនីយឯក **នួន សុខ** អនុរដ្ឋលេខាធិការក្រសួងការពារជាតិ ជាសមាជិក

៩–ឯកឧត្តម ឧត្តមសេនីយឯក **ញឹក ប៊ុនឆៃ** នាយរងអគ្គសេនាធិការ ជាសមាជិក

១០–ឯកឧត្តម ឧត្តមសេនីយឯក **ម៉ាន់ ថៃ** នាយខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាន ជាសមាជិក

១១–ឯកឧត្តម ឧត្តមសេនីយឯក **ប៉ុល សារឿន** នាយរងអគ្គសេនាធិការ ជាសមាជិក

១២–ឯកឧត្តម ឧត្តមសេនីយឯក **មាស សុភា** នាយរងអគ្គសេនាធិការ ជាសមាជិក

១៣–ឯកឧត្តម ឧត្តមសេនីយឯក **ដៀន ដែល** នាយកទីចាត់ការអធិការកិច្ចអគ្គបញ្ជាការដ្ឋាន ជាសមាជិក

១៤–ឯកឧត្តម ឧត្តមសេនីយឯក **ប៉ុល សុត** នាយកទីចាត់ការហិរញ្ញវត្ថុអគ្គបញ្ជាការដ្ឋាន ជាសមាជិក

១៥–ឯកឧត្តម ឧត្តមសេនីយទោ **ខឹម សោភ័ណ្ឌ** នាយរងអគ្គសេនាធិការ ជាសមាជិក

១៦–ឯកឧត្តម ឧត្តមសេនីយទោ **ផាវ ផនចាន់**នាយកទីចាត់ការទូទៅអគ្គបញ្ជាការដ្ឋាន ជាសមាជិក

១៧–ឯកឧត្តម ឧត្តមសេនីយទោ **ឡុង សុភាព**នាយកទីចាត់ការយុទ្ធអគ្គបញ្ជាការដ្ឋាន ជាសមាជិក

១៨–ឯកឧត្តម ឧត្តមសេនីយទោ **លី ដេត** នាយកទីចាត់ការបុគ្គលិកអគ្គបញ្ជាការដ្ឋាន ជាសមាជិក

១៩–ឯកឧត្តម ឧត្តមសេនីយទោ **ឈុំ សុជាតិ** នាយកនាយកដ្ឋានស្រាវជ្រាវអគ្គបញ្ជាការដ្ឋាន ជាសមាជិក

២០–អ្នកអង្គម្ចាស់នរោត្តម **ចក្រាវុធ** មេបញ្ជាការទ័ពអាកាស ជាសមាជិក

២១–ឧត្តមសេនីយត្រី **ម៉ុង សំផន** នាយក នាយកដ្ឋានថវិកា ជាសមាជិក

២២–ឧត្តមសេនីយត្រី **ទាន់ ប៊ុនទី** មេបញ្ជាការរងកងរាជអាវុធហត្ថជាតិ ជាសមាជិក

មាត្រា ២ : គណៈកម្មការមានភារកិច្ចចាត់ចែងពិធីបុណ្យសព តាមប្រពៃណី និង ទំនាក់ទំនងបណ្តាស្ថាប័ន ដែលមានការពាក់ព័ន្ធ ដើម្បីដំណើរការបុណ្យសពនេះអោយបានអធិកអធម ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ អគ្គបញ្ជាការដ្ឋាន និង សាមីខ្លួនត្រូវអនុវត្តន៍ តាមសេចក្តីសំរេចនេះ ចាប់ពីឡាយ ព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

II ការងារបណ្តាក្រសួង

១–ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៨០ សហវ. ប្រក

ស្តីពីការបង្កើតគណៈកម្មការបច្ចេកទេសម្របសំរួល

និងកែទំរង់រដ្ឋបាលប្រចាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

–បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

–បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាស

អោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស.រកម ០១៩៦.១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញលិខិតលេខ ២៦៧ សជណគបរ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីពីសំណើ រៀបចំគណៈកម្មការបច្ចេកទេសកែទំរង់រដ្ឋបាលតាមក្រសួង និង រដ្ឋលេខាធិការដ្ឋានរបស់ ទីស្តីការគណៈរដ្ឋមន្ត្រី ។
- បានឃើញតំរូវការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ :បង្កើតគណៈកម្មការបច្ចេកទេសសម្របសំរួល និង កែទំរង់រដ្ឋបាលប្រចាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដែលមានសមាសភាពដូចខាងក្រោម ÷

-ឯកឧត្តម **ឆាយ ថន**	អនុរដ្ឋលេខាធិការ	សហប្រធាន
-ឯកឧត្តម **ជា ម៉េងឈាង**	អនុរដ្ឋលេខាធិការ	
-លោក **សារាក់ ខាន់**	នាយកខុទ្ទកាល័យ	អនុប្រធាន
-លោក **មោក សុធារិន**	ប្រធាននាយកដ្ឋានបុគ្គលិក	អនុប្រធាន
-លោក **ឱុច ឡេង**	ប្រធាននាយកដ្ឋានថវិការដ្ឋ	សមាជិក
-លោក **ស ឃួរ**	នាយកទីចាត់ការគយរដ្ឋាករ	សមាជិក
-លោក **ខិន ឃន**	ប្រធានរតនាគារជាតិ	សមាជិក
-លោក **សាម ម៉ិនហេង**	ប្រធាននាយកដ្ឋានហិរញ្ញកិច្ច	សមាជិក
-លោក **យីនន៍ ស័យឈន់**	ប្រធាននាយកដ្ឋានរបបគណនេយ្យ	សមាជិក
-លោក **ហុង ថា**	ប្រធាននាយកដ្ឋានពន្ធដារ	សមាជិក

- លោក ជូ គីមឡេង ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស សមាជិក
- លោក ច្រាក់ ឡេង ប្រធានអង្គភាពមន្ទីរ សមាជិក
- លោក ទេព វិជោទុន្ស នាយកសាលាមធ្យមសិក្សាហិរញ្ញវត្ថុ សមាជិក
- លោក ក៉េង លាងច័ណ្ឌ ប្រធាននាយកដ្ឋានទុនវិនិយោគក្នុងមាតុស្ថាន សមាជិក
- លោក ស៊ុន គីមស៊្រុន អនុប្រធាននាយកដ្ឋានទុនវិនិយោគក្នុងមាតុស្ថាន សមាជិក
- លោក អ៊ុន ក៉េងអ៊ីម ប្រធានក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា សមាជិក
- លោក នួច ហៃ ប្រធានការិយាល័យបុគ្គលិក សមាជិក
- លោក ស៊ុន ចន្ថ្រី ប្រធានការិយាល័យគ្រប់គ្រងថវិកា សមាជិក

ប្រការ ២ : គណៈកម្មការបច្ចេកទេសសំរបសំរួល និង កែទំរង់រដ្ឋបាលប្រចាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចចូលរួមសហការ និង បង្កលក្ខណៈងាយស្រួលដល់គណៈប្រតិភូរបស់ គណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង ដើម្បីកែទំរង់រដ្ឋបាលដោយមានការចូលរួមពីអ្នកជំនាញការ UNDP សំរេចភារកិច្ចជោគជ័យលើការងារកែទំរង់រដ្ឋបាលនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ៣ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានមន្ទីរ និង សាមីខ្លួនដូចក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៧១ សហវ.ប្រក

ការបង្កើតការិយាល័យពត៌មានវិទ្យា

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ

រដ្ឋាភិបាលកម្ពុជា ។

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស.រកម ០១៩៦.១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២..នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និង ច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៨.នស,៩៤ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះព្រះរាជក្រមលេខ ១១.នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជស.រកម.០៩៩៥.០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសំណើរបស់ប្រធាននាយកដ្ឋានពន្ធដារ ។

សំរេច

ប្រការ ១ : ត្រូវបានបង្កើតក្នុងនាយកដ្ឋានពន្ធដារនូវការិយាល័យពត៌មានវិទ្យា

ប្រការ ២ : ការិយាល័យនេះមានភារកិច្ច :

- កំណត់នយោបាយទូទៅរបស់នាយកដ្ឋានពន្ធដារអំពីពត៌មានវិទ្យា និង ចូលរួមធ្វើអោយនយោបាយនេះដំណើរការបានល្អ
- សិក្សាស្រាវជ្រាវពត៌មាននៃផ្នែកទាំងឡាយ
- កំណត់សេចក្តីត្រូវការ នៃការអនុវត្តន៍ពត៌មានវិទ្យា និង ចូលរួមធ្វើអោយដំណើរការនូវគំរោងពត៌មានសារពើពន្ធ

ប្រការ ៣ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ និង អង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៧២ ប្រក.សហវ.ពដ

ការបង្កើតការិយាល័យបទិនាន

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រឹត្យ ន.ស.រកត ១០៩៤.៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស.រកម ០១៩៦.១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និងច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៨ ន.ស ៩៤ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១.នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ច្បាប់ស្តីកាកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយ

ប្រើដោយព្រះរាជក្រម ជស.រកម.០៩៩៥.០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥

- បានឃើញតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសំណើរបស់ប្រធាននាយកដ្ឋានពន្ធដារ ។

សំរេច

ប្រការ ១ : ត្រូវបានបង្កើតក្នុងនាយកដ្ឋានពន្ធដារ នូវការិយាល័យវិវាទ ។

ប្រការ ២ : ការិយាល័យនេះមានភារកិច្ច ។

- គ្រប់គ្រងរាល់វិវាទកើតមានឡើងរវាងអ្នកជាប់ពន្ធ និង រដ្ឋបាលសារពើពន្ធ
- ស្វែងយល់លើរាល់ការតវ៉ារបស់អ្នកជាប់ពន្ធ ចំពោះគ្រប់កិច្ចការដែលជាសមត្ថកិច្ចផ្ទាល់របស់នាយកដ្ឋាន និង ការតវ៉ាទាំងឡាយដែលមិនអាចដោះស្រាយបាននៅក្នុងក្របខ័ណ្ឌមូលដ្ឋាន
- រៀបចំសេចក្តីសំរេចរបស់លោកប្រធាន ឬ សេចក្តីសំរេចទាំងឡាយ សំរាប់ដាក់ជូនរដ្ឋមន្ត្រីទៅតាមសមត្ថកិច្ច
- ធានាទំនាក់ទំនងជាមួយនឹងតុលាការ
- រៀបចំចាត់តែងជាផលប្រយោជន៍ដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លើរាល់ពាក្យបណ្តឹងធ្វើឡើងដោយក្រសួងទៅតុលាការ
- ប្រមូលផ្តុំរាល់ស្ថិតិវិវាទ ពាក់ព័ន្ធដល់មូលដ្ឋានកំណត់ពន្ធ ។

ប្រការ ៣ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ និង អង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៧៤ ប្រក.សហវ.គរ

ស្តីពីការតែងតាំង និង ផ្ទេរភារកិច្ចមន្ត្រីគយនិងរដ្ឋាករ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញ ព្រះរាជក្រឹត្យរបស់ ព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាល ។
- បានឃើញ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស.រកម.០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញសារាចរស្តីពីការគ្រប់គ្រងមន្ត្រីរាជការគយនិងរដ្ឋាករ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០១សរ.សហវ.គរ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៥
- យោងតាមការឯកភាពរបស់ឯកឧត្តមរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នាថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៦ ។
- យោងការងារចាំបាច់របស់ក្រសួង ។

សម្រេច

ប្រការ១ : ធ្វើការតែងតាំងមន្ត្រីគយនិងរដ្ឋាករ ដូចមានរាយនាមខាងក្រោមនេះ

១- លោក **អ៊ុយ [illegible]** បច្ចុប្បន្នអនុប្រធានទីស្នាក់ការគយនិងរដ្ឋាករ ក្រុងព្រះសីហនុ ត្រូវបានតែងតាំងជាអនុប្រធានសាខាគយនិងរដ្ឋាករខេត្តស្ទឹងត្រែង ទទួលបន្ទុកក្តាប់រួម

២- លោក **ម៉ិត សារឿន** បច្ចុប្បន្នជាអនុប្រធានទីស្នាក់ការគយនិងរដ្ឋាករផែក្រុងព្រះសីហនុ ត្រូវបានតែងតាំងជាអនុប្រធានសាខាគយនិងរដ្ឋាករខេត្តតាកែវ ។

៣–លោក ឃុន រ៉ាន់ បច្ចុប្បន្នជាអនុប្រធានទីស្នាក់ការគយ និងរដ្ឋាករបាក់ខ្លង ត្រូវបាន តែងតាំងជាអនុប្រធានសាខាគយ និងរដ្ឋាករខេត្ត ស្ទឹងត្រែង

